# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ ជីវវិទ្យា
- ថ្នាក់ទី ៖ ៩
- ជំពូកទី៤ ៖ ភ្នាក់ងារបង្ករោគ និងជំងឺ
- មេរៀនទី២ ៖ ជំងឺឆ្លង
- ម៉ោងទី៥
- ប្រធានបទ ៖ **ជំងឺឆ្លង**
- រយៈពេល ៖ ០១ម៉ោងសិក្សា (៥០នាទី)

បង្រៀនដោយ ៖..........................................................

**I. វត្ថុបំណង ៖**

- ចំណេះដឹង ៖ សិស្សអាចកំណត់និយមន័យបានត្រឹមត្រូវ ពីជំងឺអេដស៍តាមរយៈខ្លឹមសាររបស់មេរៀន
- បំណិន ៖ សិស្សពន្យល់បានច្បាស់លាស់ ពីជំងឺអេដស៍តាមរយៈខ្លឹមសាររបស់ មេរៀន
- ឥរិយាបថ ៖ បណ្តុះស្មារតីសិស្ស អោយមានការប្រុងប្រយ័ត្ន ពីការឆ្លងនៃមេរោគអេដស៍ និង ជំងឺអេដស៍

**II. សម្ភារៈបង្រៀន និងរៀន ៖**

**- ឯកសារយោង ៖**

+ សៀវភៅពុម្ពសិស្សថ្នាក់ទី៩ មុខវិជ្ជាជីវវិទ្យារបស់ក្រសួងអប់រំ បោះពុម្ពផ្សាយ នៅឆ្នាំ២០១៤។

+ សៀវភៅណែនាំសម្រាប់គ្រូបង្រៀន របស់ STEPSAM2។

+ ឯកសារណែនាំគ្រូបង្រៀន របស់ VSO។

**- សម្ភារៈពិសោធន៍/សម្ភារឧបទេស ៖**

+ ផ្ទាំងរូបភាព

+ ប័ណ្ណសំនួរ

*** កំណត់សម្គាល់ ៖**

+ ..............................................................................................................

**III. សកម្មភាពបង្រៀន និងរៀន ៖**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្តាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្របសម្រួលឡើងរាយការណ៍ពីអវត្តមានសិស្ស។ |

| | | |
|---|---|---|
| - តើកាលពីថ្ងៃមុន យើងបានរៀន ពីមេរៀនអ្វី?<br>- ដូចម្ដេចដែលហៅថា ជំងឺឆ្លង?<br><br>- តើជំងឺឆ្លង ដែលប្អូនធ្លាប់ស្គាល់មានជំងឺអ្វីខ្លះ? | ជំហានទី២ (៥នាទី)<br>**រំឭកមេរៀនចាស់**<br>- កាលពីថ្ងៃមុន យើងបានសិក្សាអំ ពីមេរៀនទី២ ជំងឺឆ្លង<br>- ជំងឺឆ្លង គឺជាប្រភេទជំងឺដែលឆ្លង ពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត<br>- ជំងឺឆ្លង ដែលខ្ញុំធ្លាប់ស្គាល់មាន ផ្ដាសាយ ជំងឺរបេង ជំងឺថ្លើម ជំងឺអេដស៍...។ | - កាលពីថ្ងៃមុន យើងបានសិក្សាអំ ពីមេរៀនទី២ ជំងឺឆ្លង<br>- ជំងឺឆ្លង គឺជាប្រភេទជំងឺដែលឆ្លង ពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត<br>- ជំងឺឆ្លង ដែលខ្ញុំធ្លាប់ស្គាល់មាន ផ្ដាសាយ ជំងឺរបេង ជំងឺថ្លើម ជំងឺអេដស៍...។ |
| - ថ្ងៃមុន យើងបានសិក្សាអំពី ចំណុចទី៣ និងចំណុច ៣.១ | ជំហានទី៣ (៣០នាទី)<br>**មេរៀនប្រចាំថ្ងៃ**<br>**ជំងឺឆ្លង**<br><br>៣. <u>ជំងឺអេដស៍</u><br>៣.១ <u>និយមន័យជំងឺអេដស៍</u><br>ក. <u>សំណួរគន្លឹះ</u> | |
| តើជំងឺអេដស៍ គឺជាអ្វី? | | |
| - គ្រូចែកសិស្សជា ៤ក្រុមពិភាក្សាអំពីសំណួរគន្លឹះ។<br>- គ្រូអោយសិស្សឡើងបិទរូបភាពនៅលើក្ដាខៀន។<br><br>- តើរូបភាពនេះ បង្ហាញពីអ្វី?<br><br>- ហេតុអ្វី បានជាមនុស្សស្គម?<br><br>- តើមនុស្សមានជំងឺអ្វី?<br><br>- តើជំងឺអេដស៍ បង្កឡើងដោយ វីរុសមានឈ្មោះអ្វី?<br>- គ្រូអោយសិស្សយកចម្លើយ ដែល | ខ. <u>សម្មតិកម្ម</u><br><br>គ. <u>សកម្មភាព</u> | -សិស្សចូលទៅតាមក្រុមពិភាក្សាទៅលើសំណួរគន្លឹះ។<br>- សិស្សឡើងបិទរូបភាព នៅលើក្ដាខៀន។<br><br>- រូបភាពនេះ គឺបង្ហាញពីមនុស្សស្គមម្នាក់។<br>- ហេតុបានជាមនុស្សស្គម គឺដោយសារមនុស្សមានជំងឺ។<br>- មនុស្សមានជំងឺ រាគ ថ្លើម គ្រុនពោះវៀន ក្រពះ របេង កង្វះអាហារ និងជំងឺអេដស៍ជាដើម។<br>- តើជំងឺអេដស៍ បង្កឡើងដោយវីរុសមានឈ្មោះថា HIV។ |

| | | |
|---|---|---|
| ពួកគេសរសេររួច មកបិទនៅលើ ក្ដាខៀន។ | <br>ឃ. <u>សេចក្ដីសន្និដ្ឋាន</u><br>- ជំងឺអេដស៍ គឺជាប្រជុំរោគសញ្ញា ដែលកើតឡើងក្រោយពេលប្រព័ន្ធភាពស៊ាំចុះខ្សោយ។ ជំងឺអេដស៍ បង្កឡើងដោយវីរុស មានឈ្មោះថា HIV ។ | - សិស្សយកចម្លើយ ដែលពួកគេ សរសេររួច មកបិទនៅលើក្ដាខៀន។<br><br>- ជំងឺអេដស៍ គឺជាប្រជុំរោគសញ្ញា ដែលកើតឡើងក្រោយពេលប្រព័ន្ធភាពស៊ាំចុះខ្សោយ។ ជំងឺអេដស៍ បង្កឡើងដោយវីរុស មានឈ្មោះថា HIV ។ |
| - ដូចម្ដេចដែលហៅថា ជំងឺអេដស៍? តើជំងឺអេដស៍ បង្កឡើងដោយវីរុស មានឈ្មោះអ្វី? | ជំហានទី៤ (១៥នាទី)<br>**ពង្រឹងពុទ្ធិ**<br>- ជំងឺអេដស៍ គឺជាប្រជុំរោគសញ្ញា ដែលកើតឡើងក្រោយពេលប្រព័ន្ធភាពស៊ាំចុះខ្សោយ។ ជំងឺអេដស៍ បង្កឡើងដោយវីរុស មានឈ្មោះថាHIV។ | - ជំងឺអេដស៍ គឺជាប្រជុំរោគសញ្ញា ដែលកើតឡើងក្រោយពេលប្រព័ន្ធភាពស៊ាំចុះខ្សោយ។ ជំងឺអេដស៍ បង្កឡើងដោយវីរុស មានឈ្មោះថាHIV។ |
| - គ្រូអោយសិស្សមើលមេរៀនបន្ត ជាពិសេស ត្រូវមានអនាម័យខ្លួនប្រាណ និងការរស់នៅស្អាតជាប្រចាំ។ | ជំហានទី៥ (៣នាទី)<br>**បណ្ដាំផ្ញើរ កិច្ចការផ្ទះ** | - សិស្សស្ដាប់ និងអនុវត្តតាមការណែនាំរបស់គ្រូរៀងៗខ្លួន។ |